ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

-សាលក្រមព្រហ្មទណ្ឌ
លេខៈ ១៣១ "គ១ក្រ១០"
ចុះថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ២០២៣
-សំណុំរឿងព្រហ្មទណ្ឌ
លេខៈ ១៣៤៧
ចុះថ្ងៃទី ១៨ ខែ មីនា ឆ្នាំ២០២២
-សំណុំរឿងស៊ើបសួរ
លេខៈ ១០៣១
ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ២០២២
-សំណុំរឿងជំនុំជម្រះ
លេខៈ ៣៤២២
ចុះថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ២០២២

## តាមនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងរាជធានីភ្នំពេញ

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ២០២៣ វេលាម៉ោង ០២:៣០ នាទីរសៀល នៅសាលសវនាការសាលាដំបូងរាជធានីភ្នំពេញ ដោយមានសមាសភាព៖

### ក្រុមប្រឹក្សាជំនុំជម្រះ

-លោកស្រី [redacted] ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ ប្រធានក្រុមប្រឹក្សា។
-លោក [redacted] អនុប្រធានសាលាដំបូងរាជធានីភ្នំពេញ ចៅក្រមប្រឹក្សា។
-លោក [redacted] ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ ចៅក្រមប្រឹក្សា។

### តំណាងអយ្យការ

-លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញ។

### ក្រឡាបញ្ជីសវនាការ

-លោក [redacted] ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ។

### មេធាវីការពារឱ្យជនជាប់ចោទ

-មេធាវី [redacted]
-មេធាវី [redacted]។

ដើម្បីជំនុំជម្រះលើ **សំណុំរឿងព្រហ្មទណ្ឌលេខ ១៣៤៧ ចុះថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ២០២២** ដែលមានជនជាប់ចោទ៖

១- ឈ្មោះ [redacted] **ករុណា** ហៅចេក ភេទប្រុស អាយុ២៤ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ សាសនាព្រះពុទ្ធ មុខរបររើសអេតចាយ ទីកន្លែងកំណើតនៅ [redacted] រាជធានីភ្នំពេញ មានទីលំនៅមុនពេលឃុំខ្លួនស្នាក់នៅផ្ទះជួល ផ្លូវបេតុង ភូមិតាង៉ូវ សង្កាត់និរោធ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ ប្រពន្ធឈ្មោះ [redacted] ម៉ាក់លីម មានកូនចំនួន០១នាក់ ឪពុកឈ្មោះ [redacted] ឌី "ស្លាប់" ម្ដាយឈ្មោ[redacted] វ៉ាន់នី "រស់" ជានីតិជន ទោសពីមុន គ្មាន។ (ក្នុងឃុំ-PJ)

តាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ២២១០ "អ" ដ.យ.ដ ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ២០២២។

២- ឈ្មោះ [redacted] **វិសាល** ហៅញ៉ុញ ភេទប្រុស អាយុ២១ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ សាសនាព្រះពុទ្ធ មុខរបររត់តុក់ៗ ទីកន្លែងកំណើតនៅ [redacted] ខេត្តកណ្ដាល មានទីលំនៅមុនពេលឃុំខ្លួនស្នាក់នៅផ្ទះគ្មានលេខ ផ្លូវបេតុង ភូមិដើមស្លែង សង្កាត់ច្បារអំពៅ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] ញ៉ាញ់ "រស់" ម្ដាយឈ្មោះ [redacted] សាវិន "រស់" នៅលីវ ជានីតិជន ទោសពីមុនគ្មាន។ (ក្នុងឃុំ-PJ)

តាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ២២០៩ "អ" ដ.យ.ដ ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០២២។

ជាប់ចោទពីបទ៖ **លួចមានស្ថានទម្ងន់ទោស និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុចមុខដីឡូត៍គ្មានលេខ ផ្លូវបេតុង ភូមិដើមស្លែង សង្កាត់ច្បារអំពៅ២ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ កាលពីថ្ងៃទី០៩ ខែមីនា

ឆ្នាំ២០២២ ដែលមានបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

៣- ឈ្មោះ [redacted] ឌី ហៅឌី ភេទប្រុស អាយុ៣៤ឆ្នាំ(កើតឆ្នាំ១៩៨៨) ជនជាតិខ្មែរ សញ្ជាតិខ្មែរ សាសនាព្រះពុទ្ធ មុខរបរកម្មករសំណង់ ទីកន្លែងកំណើតនៅភូ[redacted] រាជធានីភ្នំពេញ មានទីលំនៅមុនពេលឃុំខ្លួនស្នាក់នៅផ្ទះជួលគ្មានលេខ ផ្លូវលេខ៣៥៧ ក្រុមទី៤ ភូមិដើមស្លែង១ សង្កាត់ច្បារអំពៅ២ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ ប្រពន្ធឈ្មោះ[redacted] ហ៊ីន គ្មានកូន ឪពុកឈ្មោះ[redacted] ខន "រស់" ម្តាយឈ្មោះ [redacted]សារឿន "រស់" ជានីតិជន ទោសពីមុន គ្មាន។ (ក្នុងឃុំ)

តាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ១០៣១៣ "គ១" ដ.ឃ.ង ចុះថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ២០២២។

៤- ឈ្មោះ [redacted] ចាន់ធី ភេទប្រុស អាយុ២០ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មុខរបរ រើសអេតចាយ ទីកន្លែងកំណើតនៅ ភូមិ[redacted] រាជធានីភ្នំពេញ មានទីលំនៅឃុំខ្លួនស្នាក់នៅផ្ទះជួលគ្មានលេខ ផ្លូវបេតុង ភូមិដើមស្លែង សង្កាត់ច្បារអំពៅ២ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ ឪពុកឈ្មោះ គឿន ម្តាយឈ្មោះ ម៉ៅ "រស់" នៅលីវ ជានីតិជន ទោសពីមុនគ្មាន។ (ក្នុងឃុំ)

តាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ៨៧៤៨ "គ១" ដ.ឃ.ង ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០២២។

ជាប់ចោទពីបទ៖ **លួចមានស្ថានទម្ងន់ទោស** ប្រព្រឹត្តនៅចំណុចមុខដីឡូតិ៍គ្មានលេខ ផ្លូវបេតុង ភូមិដើមស្លែង សង្កាត់ច្បារអំពៅ២ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ កាលពីថ្ងៃទី០៩ ខែមីនា ឆ្នាំ២០២២ ដែលមានបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ។

ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សំបូរ ភេទប្រុស អាយុ៤០ឆ្នាំ មានទីលំនៅបច្ចុប្បន្នផ្ទះជួល ផ្លូវលេខ ៥ ក្រុមទី៧ ភូមិក្រោលគោ សង្កាត់គីឡូម៉ែត្រលេខ៦ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ

## <u>**អង្គហេតុនៃរឿងមានដូចតទៅ**</u>

កាលពីថ្ងៃទី០៩ ខែមីនា ឆ្នាំ២០២២ វេលាម៉ោង ២១ និង ០០ នាទី នៅចំណុចមុខដីឡូត៍គ្មានលេខ ផ្លូវបេតុង ភូមិដើមស្លែង សង្កាត់ច្បារអំពៅ២ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ មានជនត្រូវចោទ០៥ នាក់ ១-ឈ្មោះ[redacted]ករុណា ហៅចេក ភេទប្រុស អាយុ២៤ឆ្នាំ ២-ឈ្មោះ [redacted] វិសាល ហៅញ៉ញ ភេទប្រុស អាយុ២១ឆ្នាំ ៣-ឈ្មោះ ឌី ភេទប្រុស អាយុប្រហែល៣១ឆ្នាំ ៤-ឈ្មោះ ចាន់ធី ភេទប្រុស អាយុប្រហែល២៣ឆ្នាំ និង ៥-ឈ្មោះ ឆក ភេទប្រុស អាយុប្រហែល៣០ឆ្នាំ បានជិះម៉ូតូម៉ាកហុងដាស១០០កូរ៉េ ពណ៌ខ្មៅ គ្មានផ្លាកលេខ មានសណ្តោងរ៉ឺម៉ក បានធ្វើសកម្មភាពវាយទៅលើជនរងគ្រោះឈ្មោះ [redacted] សំបូរ ភេទប្រុស អាយុ៤០ឆ្នាំ ដែលបានជិះម៉ូតូចេញពីកន្លែងធ្វើការទៅលេងផ្ទះនៅ សង្កាត់ស្វាយប៉ាក ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ និងបានឈប់ម៉ូតូដើម្បីបត់ជើងតូចត្រង់ចំណុចកើតហេតុខាងលើ ដោយក្រុមជនត្រូវចោទបានវាយដោយដំបងឈើមូល និងទាត់ជនរងគ្រោះបណ្តាលឱ្យរបួសថ្ពាល់ខាងស្តាំនិងបែកច្រមុះដួលសន្លប់លើដី រួចក៏បានយកទូរស័ព្ទដៃមួយគ្រឿងម៉ាក វីវ៉ូមី ពណ៌ខ្មៅ និង ប្រាក់ចំនួន៥០,០០០៛ (ប្រាំម៉ឺនរៀល) រួចក៏នាំគ្នាគេចខ្លួនអស់។ លុះដល់ថ្ងៃទី១០ ខែមីនា ឆ្នាំ២០២២ ជនរងគ្រោះខាងលើក៏បានទៅដាក់ពាក្យបណ្តឹងនៅទីស្នាក់ការប៉ុស្តិ៍ច្បារអំពៅ២ រហូតដល់ថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២២ វេលាម៉ោង ១៦ និង ០០ នាទី សមត្ថកិច្ចក៏បានធ្វើការឃាត់ខ្លួនជនត្រូវចោទឈ្មោះ[redacted] ករុណា ហៅចេក នៅភូមិដើមស្លែង សង្កាត់ច្បារអំពៅ២ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ និង បានដកហូតម៉ូតូ០១ គ្រឿងមានសណ្តោងរ៉ឺម៉ក ដែលជនត្រូវចោទបានប្រើប្រាស់ក្នុងការធ្វើសកម្មភាព រួចបានបញ្ជូនមកប៉ុស្តិ៍ច្បារអំពៅ២ ដើម្បីសាកសួរ។ ក្រោយមកនៅថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២២ ម៉ោង ១២ និង ៣០ នាទី សមត្ថកិច្ចក៏បន្តឃាត់បានជនត្រូវចោទឈ្មោះ [redacted] វិសាល ហៅញ៉ញ ភេទប្រុស អាយុ២១ឆ្នាំ នៅចំណុច ភូមិកណ្តាល សង្កាត់ច្បារអំពៅ២ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ។ ចំណែកជនត្រូវចោទ ០៣នាក់ ឈ្មោះ ឌី , ឈ្មោះ [redacted] ធី និងឈ្មោះ ឆក បានយកទូរស័ព្ទជនរងគ្រោះ ខាងលើគេច

ខ្លួនបាត់។ បន្ទាប់ពីសាកសួររួច សមត្ថកិច្ចក៏បានធ្វើតេស្តទឹកនោមស្វែងរកសារធាតុញៀន លើជនត្រូវចោទទាំងពីរជាលទ្ធផលបង្ហាញថា វិជ្ជមាន (មានសារធាតុញៀនក្នុងទឹកនោម) ពិតប្រាកដមែន។

បានឃើញរបាយការណ៍សំយោគលេខ ០៣៦/២២ រ.ប.ក ចុះថ្ងៃទី ១៧ ខែ មីនា ឆ្នាំ២០២២ របស់អធិការដ្ឋាននគរបាលខណ្ឌច្បារអំពៅ។

បានឃើញដីកាសន្និដ្ឋានស្ថាពរលេខ ៣០៣៧ អ.យ.ធ ចុះថ្ងៃទី១២ ខែ សីហា ឆ្នាំ២០២២ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

បានឃើញដីកាបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ ៤២០៤ "យ" ស.ង ចុះថ្ងៃទី ២៤ ខែ សីហា ឆ្នាំ២០២២ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ។

## <u>នាពេលសវនាការ</u>

ជនជាប់ចោទឈ្មោះ[redacted]ករុណា ហៅចេក បានឆ្លើយថា៖កាលពីថ្ងៃទី០៩ ខែមីនា ឆ្នាំ២០២២ វេលាម៉ោង២១និង០០នាទី រូបខ្លួន, ឈ្មោះ ញ៉ុញ ([redacted] វិសាល) ,ឈ្មោះ ឌី ភេទប្រុស អាយុប្រហែល ៣១ឆ្នាំ, ឈ្មោះ ចាន់ធី ភេទប្រុស អាយុប្រហែល ២៣ឆ្នាំ និងឈ្មោះ ឆក ភេទប្រុស អាយុប្រហែល ៣០ឆ្នាំ ជិះម៉ូតូ ០១គ្រឿង ម៉ាកហុងដាសេ១០០ក្វូរ៉េ ពណ៌ខ្មៅ គ្មានផ្លាកលេខ មានសណ្តោងរ៉ឺម៉កមកអង្គុយលេងនៅចំណុចមុខដីឡូត៍គ្មានលេខ ភូមិដើមស្លែង សង្កាត់ច្បារអំពៅ២ ខណ្ឌច្បារអំពៅ ពេលនោះឈ្មោះ ឌី ប្រាប់ថា មានមនុស្សម្នាក់មិនស្គាល់ឈ្មោះ អាយុប្រហែលជាង ៤០ឆ្នាំ កំពុងបត់ជើងតូច រួចពួកខ្លួនទាំង ៥នាក់ ក៏ជិះម៉ូតូសណ្តោងរ៉ឺម៉កទៅឈប់ក្បែរនោះ ដោយមានសភាពស្ងាត់ក៏ពួកខ្លួនក៏នាំគ្នាវាយ និងទាត់មនុស្សប្រុសនោះ រួចខ្លួនយកដំបងឈើមូលវាយមនុស្សប្រុសនោះបណ្តាលឱ្យរងរបួសផ្ទាល់ទាំងសងខាង និងបែកច្រមុះដួលសន្លប់លើដី ពេលនោះឈ្មោះ ឌី ក៏យកបានទូរស័ព្ទដៃ ០១គ្រឿង មិនស្គាល់ម៉ាក ពណ៌ខ្មៅ និងប្រាក់ចំនួន ៥០,០០០៛(ប្រាំម៉ឺនរៀល) នាំគ្នាគេចខ្លួនយកដំបងឈើបោះចោលក្នុងព្រៃបាត់ រួចយកប្រាក់ទៅទិញគ្រឿងញៀនជក់អស់។ លុះដល់ថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២២ វេលាម៉ោង១៦និង០០នាទី រូបខ្លួនកំពុងនៅភូមិដើមស្លែង សង្កាត់ច្បារអំពៅ២ ខណ្ឌច្បារអំពៅ ក៏មានសមត្ថកិច្ចមកដល់ឃាត់រូបខ្លួន ដកហូត ម៉ូតូ០១គ្រឿង មានសណ្តោងរ៉ឺម៉ក បញ្ជូនមកកាន់ទីស្នាក់ការប៉ុស្តិ៍ច្បារអំពៅ២តែម្តង។ ចំណែកឈ្មោះ ឌី និងឈ្មោះ ឆក និងឈ្មោះ ចាន់ធី យកទូរសព្ទដៃគេចខ្លួនបាត់។ កន្លងមករូបខ្លួនធ្លាប់ប្រើប្រាស់គ្រឿងញៀនរយៈពេល០២ឆ្នាំ។

ជនជាប់ចោទឈ្មោះ[redacted] វិសាល ហៅញ៉ុញ បានឆ្លើយថា៖ កាលពីថ្ងៃទី០៩ ខែមីនា ឆ្នាំ២០២២ ម៉ោង២១ និង០០នាទី រូបខ្លួន,ឈ្មោះ ចេក [redacted]ករុណា ហៅចេក) ឈ្មោះ ឌី ភេទប្រុស អាយុប្រហែល ៣១ឆ្នាំ ,ឈ្មោះ ចាន់ធី ភេទប្រុស អាយុប្រហែល២៣ឆ្នាំ និងឈ្មោះ ឆក ភេទប្រុស អាយុប្រហែល ៣០ឆ្នាំ ជិះម៉ូតូ ០១ គ្រឿង ម៉ាកហុងដាសេ១០០ក្វូរ៉េ ពណ៌ខ្មៅ គ្មានផ្លាកលេខ មានសណ្តោងរ៉ឺម៉កមកអង្គុយលេងនៅចំណុចមុខដីឡូត៍គ្មានលេខ ភូមិដើមស្លែង សង្កាត់ច្បារអំពៅ២ ខណ្ឌច្បារអំពៅ ពេលនោះឈ្មោះ ឌី ប្រាប់ថា មានមនុស្សម្នាក់មិនស្គាល់ឈ្មោះ អាយុប្រហែលជាង ៤០ឆ្នាំ កំពុងបត់ជើងតូច រួចពួកខ្លួនទាំង ០៥នាក់ ក៏ជិះម៉ូតូសណ្តោងរ៉ឺម៉កទៅឈប់ក្បែរនោះ ដោយមានសភាពស្ងាត់ក៏ពួកខ្លួនក៏នាំគ្នាវាយ និងទាត់មនុស្សប្រុសនោះ រួចឈ្មោះ ចេក ក៏យកដំបងឈើមូលវាយមនុស្សប្រុសនោះបណ្តាលឱ្យរងរបួសផ្ទាល់ទាំងសងខាង និងបែកច្រមុះដួលសន្លប់លើដី ពេលនោះខ្លួនក៏យកបានទូរស័ព្ទដៃ០១គ្រឿង មិនស្គាល់ម៉ាក ពណ៌ខ្មៅ និងប្រាក់ចំនួន ៥០,០០០៛ (ប្រាំម៉ឺនរៀល) នាំគ្នាគេចខ្លួន រួចយកប្រាក់ទៅទិញគ្រឿងញៀនជក់អស់។ លុះដល់ថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២២ វេលាម៉ោង ១២ និង ៣០ នាទី ខ្លួនកំពុងនៅចំណុចភូមិកណ្តាល សង្កាត់ច្បារអំពៅ២ ខណ្ឌច្បារអំពៅ ក៏មានសមត្ថកិច្ចមកដល់ឃាត់រូបខ្លួនបញ្ជូនមកកាន់ទីស្នាក់ការ ប៉ុស្តិ៍ច្បារអំពៅ២ តែម្តង។ ចំណែកឈ្មោះ ឌី ,ឈ្មោះ ឆក និងឈ្មោះ ចាន់ធី យកទូរសព្ទដៃគេចខ្លួនបាត់។ កន្លងមករូបខ្លួនធ្លាប់ប្រើប្រាស់គ្រឿងញៀនរយៈពេល០២ឆ្នាំ។



Scanned with CamScanner

ជនជាប់ចោទឈ្មោះ [redacted] ឌី បានឆ្លើយថា៖ ខ្ញុំពិតជាបានប្រព្រឹត្តដូចការចោទប្រកាន់ប្រាកដមែន។

ជនជាប់ចោទឈ្មោះ [redacted] ចាន់ឌី បានឆ្លើយថា៖ ខ្ញុំពិតជាបានប្រព្រឹត្តដូចការចោទប្រកាន់ប្រាកដមែន។

ក្រឡាបញ្ជីអានអំណានចម្លើយរបស់ឈ្មោះ [redacted] សំបូរ បានឆ្លើយថា៖ កាលពីថ្ងៃទី០៩ ខែ មីនា ឆ្នាំ២០២២ វេលាម៉ោងប្រហែលប្រាំបួន យប់ ខ្លួនបានជិះម៉ូតូមួយគ្រឿងម្នាក់ឯង ម៉ាកហុងដាឌ្រីមពណ៌ខ្មៅ ផលិតឆ្នាំ២០០៧ ពាក់ផ្លាកលេខភ្នំពេញ1P-3391 មកដល់ចំណុចកើតហេតុមុខដីឡូតិ៍គ្មានលេខ ផ្លូវបេតុង ភូមិដើមស្លែង សង្កាត់ច្បារអំពៅទី២ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ ខ្លួនក៏បានឈប់ម៉ូតូបម្រុងបត់ជើងតូច ដោយពុំទាន់បានបត់ជើងផងគ្រាន់តែទ្រលម៉ូតូ ក៏ស្រាប់តែជនល្មើសមានគ្នាប្រហែលប្រាំ ទៅប្រាំមួយនាក់ ជាអ្នករស់នៅក្នុងភូមិជាមួយ (មិនស្គាល់ឈ្មោះ ស្គាល់តែមុខ) បានយកដែកមកវាយចំមុខខ្លួនបណ្ដាលឱ្យរងរបួសបាក់ធ្មេញដាក់ចំនួនដប់ដើម របះមាត់ចេញឈាម ត្រូវចំក្តោងច្រមុះ និងថ្ពាសជាំខ្លាំងធ្វើឱ្យខ្លួនបានដួលទៅដីមួយភ្លែត ហើយពួកវាបានយកដាវមកកាប់លើខ្លួន តែត្រូវប្អូនធម៌មកទាន់បានចូលមករងជិនួសខ្លួន ហើយធ្វើឱ្យពួកវាកាប់ត្រូវប្អូនធម៌របះ ត្រូវចំខាងក្រោយក្បាលភ្លាមៗនោះ ក៏ពួកវាឡើងម៉ូតូរ៉ឺម៉កគេចខ្លួនតែម្ដង។ នៅក្នុងហេតុការណ៍នោះ ពួកជនល្មើសបានយករបស់របរខ្លួន ដូចជា: លុយចំនួន ៥០,០០០៛ (ប្រាំម៉ឺនរៀល និងទូរស័ព្ទដៃម៉ាករ៉ែមចំនួនមួយគ្រឿង តម្លៃ១៦០ដុល្លារអាមេរិក ។ ក្រៅពីនេះមិនបានបាត់បង់អ្វីទៀតទេ។

## សេចក្ដីសន្និដ្ឋានម្ដឹងសុំរបស់តំណាងអយ្យការ

តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា: ក្រោយពីបានពិនិត្យសំណុំរឿងចប់សព្វគ្រប់ ស្ដាប់ចម្លើយរបស់ជនជាប់ចោទ , ចម្លើយរបស់ដើមបណ្ដឹង និងភស្តុតាងនានាដែលមាននៅក្នុងសំណុំរឿង រួចមក ដូចនេះតំណាងអយ្យការយល់ឃើញថា ជនជាប់ចោទ ១.ឈ្មោះ [redacted]ករុណា ភេទប្រុស អាយុ២៤ឆ្នាំ ២.ឈ្មោះ [redacted] វិសាល ភេទប្រុស អាយុ២១ឆ្នាំ ៣.ឈ្មោះ [redacted] ឌី ភេទប្រុស អាយុ៣៤ឆ្នាំ ៤.ឈ្មោះ [redacted] ចាន់ឌី ភេទប្រុស អាយុ២០ឆ្នាំ ពិតជាបានប្រព្រឹត្តដូចការចោទប្រកាន់ប្រាកដមែន។ ដូច្នេះ តំណាងអយ្យការសុំតម្កល់ការចោទប្រកាន់ទុកនៅដដែល សូមឱ្យតុលាការពិនិត្យពិចារណា និងសម្រេចតាមច្បាប់។

## សេចក្ដីសន្និដ្ឋានរបស់មេធាវីការពារក្ដីឱ្យជនជាប់ចោទ

មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] ករុណា ឈ្មោះ [redacted] វិសាល ឈ្មោះ [redacted] ឌី និងឈ្មោះ [redacted] ចាន់ឌី សេចក្តីសន្និដ្ឋានថា:កាលពីថ្ងៃទី០៩ ខែមីនា ឆ្នាំ២០២២ វេលាម៉ោង ២១ និង ០០ នាទី នៅចំណុចមុខដីឡូតិ៍គ្មានលេខ ផ្លូវបេតុង ភូមិដើមស្លែង សង្កាត់ច្បារអំពៅ២ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ មានជនត្រូវចោទ ០៥នាក់ ០១.ឈ្មោះ [redacted] ករុណា ហៅចេក ០២.ឈ្មោះ [redacted] វិសាល ហៅញ៉ុញ ០៣.ឈ្មោះ [redacted] ឌី ហៅឌី ០៤.ឈ្មោះ [redacted] ចាន់ឌី ហៅឌី និង០៥. ឈ្មោះ ឆក បានជិះម៉ូតូម៉ាកហុងដាសេ១០០កូរ៉េ ពណ៌ខ្មៅ គ្មានផ្លាកលេខ មានសណ្តោងរ៉ឺម៉ក បានធ្វើសកម្មភាពវាយទៅលើជនរងគ្រោះឈ្មោះ [redacted] សំបូរ ដែលបានឈប់ម៉ូតូដើម្បីបត់ជើងតូចត្រង់ចំណុចកើតហេតុខាងលើដោយក្រុមជនត្រូវចោទបានវាយដោយដំបងឈើមូល និងទាត់ជនរងគ្រោះបណ្ដាយឱ្យរបួសផ្ទាល់ខាងស្ដាំ និងបកច្រមុះដួលសន្លប់លើដី រួចក៏បានយកទូរស័ព្ទមួយគ្រឿងម៉ាក រ៉ែមមី ពណ៌ខ្មៅ និងប្រាក់ចំនួន ៥០,០០០៛ (ប្រាំពាន់រៀល) រួចក៏នាំគ្នាគេចខ្លួនបានទៅ។ បន្ទាប់ពីសាកសួររួច សមត្ថកិច្ចក៏បានធ្វើតេស្តទឹកនោមស្វែងរកសារធាតុញៀនលើជនត្រូវចោទទាំងពីរជាលទ្ធផលបង្ហាញថា វិជ្ជមាន (មានសារធាតុញៀនក្នុងទឹកនោម) ពិតប្រាកដមែន។

**-អង្គច្បាប់**

យោងតាម មាត្រា៩៣ នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា បានចែងថា"កាលណាកាលៈទេសៈនៃបទល្មើស ឬបុគ្គលិកលក្ខណៈនៃជនជាប់ចោទតម្រូវ តុលាការអាចសម្រេចឱ្យជនជាប់ចោទទទួលបានស្ថានសម្រាលទោស"។



Scanned with CamScanner

មាត្រា ១០៦ នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា បានចែងថា "ក្នុងករណីដែលមានការចោទប្រកាន់ពីបទឧក្រិដ្ឋ ឬបទមជ្ឈិមនោះ ការព្យួរទោសធម្មតាអាចត្រូវផ្តល់ឱ្យបាន ប្រសិនបើជនជាប់ចោទមិនទាន់មានការ ផ្តន្ទាទោសជាស្ថាពរឱ្យជាប់ពន្ធនាគារក្នុងរយៈពេល ៥ (ប្រាំ) មុនអំពីល្មើស"។

និងមាត្រា ១០៧ នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា បានចែងថា "ការព្យួរទោសធម្មតា ត្រូវអនុវត្តទៅលើទោសដូចតទៅ៖ ១.ទោសដាក់ពន្ធនាគារ កាលបើទោសដែលប្រកាសនោះតិចជាង ឬស្មើនឹង ៥ (ប្រាំ)ឆ្នាំ ។"

**-សន្និដ្ឋាននិងសំណូមពរ**

ផ្អែកតាមចម្លើយរបស់កូនក្តីនាងកូនក្តីនាងខ្ញុំមានការសោកស្តាយចំពោះទង្វើដែលខ្លួនបានប្រព្រឹត្តហើយបានសារភាពនៅគ្រប់នីតិវិធីរបស់តុលាការ ដោយពុំបានបង្កការរាំងស្ទះណាមួយដល់នីតិវិធីតុលាការនោះទេហើយកូនក្តីនាងខ្ញុំក៏ពុំធ្លាប់ប្រព្រឹត្តបទល្មើសពីមុនមកនោះទេ ម្យ៉ាងវិញទៀតកូនក្តីនាងខ្ញុំ រៀនបានត្រឹមតែថ្នាក់ទី៥និងទី៧ប៉ុណ្ណោះដោយសារកូនក្តីនាងខ្ញុំរៀនបានតិច ហើយគ្មានចំណេះដឹង ទើបពួកគាត់ប្រព្រឹត្តបទល្មើសដោយខ្វះការពិចារណា។

នាងខ្ញុំស្នើសុំឱ្យតុលាការផ្តល់នៅស្ថានសម្រាលទោស និងផ្តល់ការព្យួរទោសដល់កូនក្តីរបស់នាងខ្ញុំ ដើម្បីឱ្យកូនក្តីនាងខ្ញុំមានឱកាសបានធ្វើការកែប្រែខ្លួន និងធ្វើសមាហរណកម្មចូលមករួមរស់នៅក្នុងសង្គមវិញ ។

អាស្រ័យហេតុនេះ សូម ឯកឧត្តមប្រធាន មេត្តាទទួលជ្រាប និងពិនិត្យសម្រេច ដោយក្តីអនុគ្រោះ ។

សូម ឯកឧត្តមប្រធាន មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីនាងខ្ញុំ ។

## សំដីចុងក្រោយរបស់ជនជាប់ចោទ

ជនជាប់ចោទឈ្មោះ [redacted] ករុណា ភេទប្រុស អាយុ២៤ឆ្នាំ បាននិយាយសំដីចុងក្រោយថា៖ សូមឱ្យតុលាការជួយបន្ធូរបន្ថយទោស។

ជនជាប់ចោទឈ្មោះ [redacted] វិសាល ភេទប្រុស អាយុ២១ឆ្នាំ បាននិយាយសំដីចុងក្រោយថា៖ សូមឱ្យតុលាការជួយបន្ធូរបន្ថយទោស។

ជនជាប់ចោទឈ្មោះ [redacted]ធី ភេទប្រុស អាយុ៣៤ឆ្នាំ បាននិយាយសំដីចុងក្រោយថា៖ សូមឱ្យតុលាការជួយបន្ធូរបន្ថយទោស។

ជនជាប់ចោទឈ្មោះ [redacted] ចាន់ធី ភេទប្រុស អាយុ២០ឆ្នាំ បាននិយាយសំដីចុងក្រោយថា៖ សូមឱ្យតុលាការជួយបន្ធូរបន្ថយទោស។

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ

-ក្រោយពីបានស្តាប់អំណានចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារក្តីឱ្យជនជាប់ចោទ

-ក្រោយពីបានស្តាប់សំដីចុងក្រោយរបស់ជនជាប់ចោទ

-ក្រោយពីបានពិនិត្យភស្តុតាងនានា

-ក្រោយពីបានពិនិត្យ និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

## សំអាងហេតុ

-ពិតជាមានករណី លួចមានស្ថានទម្ងន់ទោស និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន មួយបានកើតឡើងកាលពីថ្ងៃទី០៩ ខែមីនា ឆ្នាំ២០២២ នៅចំណុចមុខដីឡូតិ៍គ្មានលេខ ផ្លូវបេតុង ភូមិដើមស្លែង សង្កាត់ច្បារអំពៅ២ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ ដែលបង្កឡើងដោយជនជាប់ចោទ ១.ឈ្មោះ [redacted] ករុណា ភេទប្រុស អាយុ២៤ឆ្នាំ ២.ឈ្មោះ [redacted] វិសាល ភេទប្រុស អាយុ២១ឆ្នាំ និងករណី លួចមានស្ថានទម្ងន់ទោស មួយបានកើតឡើង កាលពីថ្ងៃទី០៩ ខែមីនា ឆ្នាំ ២០២២ នៅចំណុចមុខដីឡូតិ៍គ្មានលេខ ផ្លូវបេតុង ភូមិដើមស្លែង សង្កាត់ច្បារអំពៅ២ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ



Scanned with CamScanner

ដែលបង្កឡើងដោយជនជាប់ចោទ១.ឈ្មោះ [redacted] ឌី ភេទប្រុស អាយុ៣៤ឆ្នាំ ២.ឈ្មោះ [redacted] ចាន់ធី ភេទប្រុស អាយុ២០ឆ្នាំ ប្រាកដមែន។

-តាមចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សំបូរ នៅក្នុងរឿងនេះ ខ្លួនមិនធ្វើការប្តឹងទាមទារសំណង ជំងឺចិត្ត ថ្លៃព្យាបាល និងការខូចខាតនោះទេ ដោយសំណូមពរតុលាការអនុវត្តតាមច្បាប់ឱ្យបានធ្ងន់ធ្ងរលើជនល្មើស។

-តាមចម្លើយជនជាប់ចោទ ១.ឈ្មោះ [redacted]ករុណា ភេទប្រុស អាយុ២៤ឆ្នាំ ២.ឈ្មោះ [redacted] វិសាល ភេទប្រុស អាយុ ២១ឆ្នាំ ៣.ឈ្មោះ [redacted] ឌី ភេទប្រុស អាយុ៣៤ឆ្នាំ ៤.ឈ្មោះ [redacted] ចាន់ធី ភេទប្រុស អាយុ២០ឆ្នាំ ឃើញថា ជនជាប់ចោទ បានឆ្លើយសារភាពទទួលស្គាល់ការចោទប្រកាន់ប្រាកដមែន ដែលចម្លើយនេះស៊ីសង្វាក់ទៅ នឹងភស្តុតាងផ្សេងៗទៀតមាន នៅក្នុងសំណុំរឿង ក៏ដូចជារបាយការណ៍របស់សមត្ថកិច្ច អាចឱ្យតុលាការជឿថា ជនជាប់ចោទ១.ឈ្មោះ [redacted] ករុណា ភេទប្រុស អាយុ២៤ឆ្នាំ ២.ឈ្មោះ [redacted] វិសាល ភេទប្រុស អាយុ២១ឆ្នាំ ពិតជាបានប្រព្រឹត្តអំពើ លួចមានស្ថានទម្ងន់ទោស និង និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន និង១.ឈ្មោះ [redacted] ឌី ភេទប្រុស អាយុ៣៤ឆ្នាំ ២.ឈ្មោះ [redacted] ចាន់ធី ភេទប្រុស អាយុ២០ឆ្នាំ ពិតជាបានប្រព្រឹត្តអំពើ លួចមានស្ថានទម្ងន់ទោស ប្រាកដមែន។

-ជនជាប់ចោទឈ្មោះ [redacted] ករុណា ភេទប្រុស អាយុ២៤ឆ្នាំ បាននិយាយសំដីចុងក្រោយរបស់ខ្លួនថា សុំឱ្យតុលាការ មេត្តាជួយបន្ធូរបន្ថយទោសដល់រូបខ្លួនផង ព្រោះខ្លួនដឹងកំហុសហើយ។

-ជនជាប់ចោទឈ្មោះ [redacted] វិសាល ភេទប្រុស អាយុ២១ឆ្នាំ បាននិយាយសំដីចុងក្រោយរបស់ខ្លួនថា សុំឱ្យ តុលាការមេត្តាជួយបន្ធូរបន្ថយទោសដល់រូបខ្លួនផង ព្រោះខ្លួនដឹងកំហុសហើយ។

-ជនជាប់ចោទឈ្មោះ [redacted] ឌី ភេទប្រុស អាយុ៣៤ឆ្នាំ បាននិយាយសំដីចុងក្រោយរបស់ខ្លួនថា សុំឱ្យតុលាការ មេត្តាជួយបន្ធូរបន្ថយទោសដល់រូបខ្លួនផង ព្រោះខ្លួនដឹងកំហុសហើយ។

-ជនជាប់ចោទឈ្មោះ [redacted] ចាន់ធី ភេទប្រុស អាយុ២០ឆ្នាំ បាននិយាយសំដីចុងក្រោយរបស់ខ្លួនថា សុំឱ្យ តុលាការមេត្តាជួយបន្ធូរបន្ថយទោសដល់រូបខ្លួនផង ព្រោះខ្លួនដឹងកំហុសហើយ។

-មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] បានធ្វើសេចក្តីសន្និដ្ឋានថា៖ សូម តុលាការមេត្តាសម្រេចបន្ធូរបន្ថយទោសមកដល់កូនក្តីខ្លួនផង។

-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំថា៖ ក្រោយពីបានពិនិត្យសំណុំរឿងចប់សព្វគ្រប់ , ស្តាប់ចម្លើយ របស់ជនជាប់ចោទ , និងពិនិត្យភស្តុតាងនានាដែលមាននៅក្នុងសំណុំរឿងរួចមក តំណាងអយ្យការយល់ឃើញថា ជនជាប់ ចោទ ១.ឈ្មោះ [redacted] ករុណា ភេទប្រុស អាយុ២៤ឆ្នាំ ២.ឈ្មោះ [redacted] វិសាល ភេទប្រុស អាយុ២១ឆ្នាំ ៣.ឈ្មោះ [redacted] ឌី ភេទ ប្រុស អាយុ៣៤ឆ្នាំ ៤.ឈ្មោះ [redacted] ចាន់ធី ភេទប្រុស អាយុ២០ឆ្នាំ ពិតជាបានប្រព្រឹត្តដូចការចោទប្រកាន់ប្រាកដមែន សំណូមពរសុំឱ្យតុលាការពិចារណា និងសម្រេចតាមច្បាប់។ គប្បីតុលាការលើកយកមកពិចារណា។

-មានភស្តុតាង និងពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ [redacted] ករុណា ភេទប្រុស អាយុ២៤ឆ្នាំ ឈ្មោះ [redacted] វិសាល ភេទ ប្រុស អាយុ២១ឆ្នាំ ពីបទៈលួចមានស្ថានទម្ងន់ទោស និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចមុខ ដីឡូត៍គ្មានលេខ ផ្លូវបេតុង ភូមិដើមស្លែង សង្កាត់ច្បារអំពៅ២ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ កាលពីថ្ងៃទី០៩ ខែមីនា ឆ្នាំ ២០២២ ដែលមានបញ្ញត្តិឱ្យផ្តន្ទាទោសតាម មាត្រា៣៥៣ និងមាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ និងមាត្រា៤៥ នៃច្បាប់ស្តី ពីការត្រួតពិនិត្យគ្រឿងញៀន និង១.ឈ្មោះ [redacted] ឌី ភេទប្រុស អាយុ៣៤ឆ្នាំ ២.ឈ្មោះ [redacted] ចាន់ធី ភេទប្រុស អាយុ២០ឆ្នាំ ពីបទៈ លួចមានស្ថានទម្ងន់ទោស ប្រព្រឹត្តនៅចំណុចមុខដីឡូត៍គ្មានលេខ ផ្លូវបេតុង ភូមិដើមស្លែង សង្កាត់ច្បារអំពៅ២ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ កាលពីថ្ងៃទី០៩ ខែមីនា ឆ្នាំ២០២២ ដែលមានបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា ៣៥៣ និង មាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ។



Scanned with CamScanner

# ហេតុដូច្នេះសម្រេច

-ផ្តន្ទាទោសដាក់ពន្ធនាគារលើជនជាប់ចោទ៖

១-ឈ្មោះ [redacted] ករុណា ភេទប្រុស អាយុ២៤ឆ្នាំ (មានសាវតាជាតិដូចខាងលើ) កំណត់រយៈពេល **០៣ឆ្នាំ ០២ខែ (បីឆ្នាំ ពីរខែ)** ពីបទៈ **លួចមានស្ថានទម្ងន់ទោស និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុចមុខដីឡូតិ៍គ្មានលេខ ផ្លូវបេតុង ភូមិដើមស្ពែង សង្កាត់ច្បារអំពៅ២ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ កាលពីថ្ងៃទី០៩ ខែមីនា ឆ្នាំ២០២២ ដែលមានបញ្ញត្តិឱ្យផ្តន្ទាទោសតាម មាត្រា៣៥៣ និងមាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ និងមាត្រា៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

២-ឈ្មោះ [redacted] វិសាល ភេទប្រុស អាយុ២១ឆ្នាំ (មានសាវតាជាតិដូចខាងលើ) កំណត់រយៈពេល **០៣ឆ្នាំ ០២ខែ (បីឆ្នាំ ពីរខែ)** ពីបទៈ **លួចមានស្ថានទម្ងន់ទោស និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុចមុខដីឡូតិ៍គ្មានលេខ ផ្លូវបេតុង ភូមិដើមស្ពែង សង្កាត់ច្បារអំពៅ២ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ កាលពីថ្ងៃទី០៩ ខែមីនា ឆ្នាំ២០២២ ដែលមានបញ្ញត្តិឱ្យផ្តន្ទាទោសតាម **មាត្រា៣៥៣** និងមាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ និងមាត្រា៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

៣-ឈ្មោះ [redacted]ឌី ភេទប្រុស អាយុ៣៤ឆ្នាំ (មានសាវតាជាតិដូចខាងលើ) កំណត់រយៈពេល **០៣ឆ្នាំ(បីឆ្នាំ)** ពីបទៈ **លួចមានស្ថានទម្ងន់ទោស** ប្រព្រឹត្តនៅចំណុចមុខដីឡូតិ៍គ្មានលេខ ផ្លូវបេតុង ភូមិដើមស្ពែង សង្កាត់ច្បារអំពៅ២ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ កាលពីថ្ងៃទី០៩ ខែមីនា ឆ្នាំ២០២២ ដែលមានបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ។

៤-ឈ្មោះ [redacted] ចាន់ធី ភេទប្រុស អាយុ២០ឆ្នាំ (មានសាវតាជាតិដូចខាងលើ) កំណត់រយៈពេល **០៣ឆ្នាំ(បីឆ្នាំ)** ពីបទៈ **លួចមានស្ថានទម្ងន់ទោស** ប្រព្រឹត្តនៅចំណុចមុខដីឡូតិ៍គ្មានលេខ ផ្លូវបេតុង ភូមិដើមស្ពែង សង្កាត់ច្បារអំពៅ២ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ កាលពីថ្ងៃទី០៩ ខែមីនា ឆ្នាំ២០២២ ដែលមានបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ។

សាលក្រមនេះជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ២០២៣ ចំពោះមុខជនជាប់ចោទឈ្មោះ ១. ឈ្មោះ [redacted] ករុណា ភេទប្រុស អាយុ២៤ឆ្នាំ ២.ឈ្មោះ [redacted] វិសាល ភេទប្រុស អាយុ២១ឆ្នាំ ៣.ឈ្មោះ [redacted] ឌី ភេទប្រុស អាយុ៣៤ឆ្នាំ ៤.ឈ្មោះ [redacted] ចាន់ធី ភេទប្រុស អាយុ២០ឆ្នាំ និងប្រកាសជាសាធារណៈនៅថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៣។

ទុកសិទ្ធិប្តឹងឧទ្ធរណ៍ក្នុងរយៈពេលដែលច្បាប់កំណត់។

| **ក្រឡាបញ្ជីសវនាការ** | **ចៅក្រមប្រឹក្សា** | **ចៅក្រមប្រឹក្សា** | **ប្រធានក្រុមប្រឹក្សាជំនុំជម្រះ** |
|---|---|---|---|
| ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា |

[redacted]

"បានចម្លងត្រឹមត្រូវតាមច្បាប់ដើម"

ថ្ងៃ អង្គារ ០២កើត ខែ ផល្គុន ឆ្នាំ ខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ , ថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០២៣

**ក្រឡាបញ្ជី**

[redacted]

បានឃើញ

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]



Scanned with CamScanner